

# ពង្រឹងអំណាចដល់ក្រុមគោលដៅ

*ក្នុងចំណោមជនជាតិដើមភាគតិចទំពួន មាននៅបែបផែនដែលមានតម្លៃមួយ គឺការយកចិត្តទុកដាក់ និងការផ្តត់ផ្គង់ឲ្យគ្នាទៅវិញទៅមក។ ជាក់ស្តែងដូចបានឃើញនៅក្នុងភូមិទំពួនមួយដែលមានឈ្មោះថាកាម៉ែន នៅក្នុងខេត្តរតនគិរី អ្នកភូមិធ្វើសកម្មភាពយ៉ាងស្វាហាប់ ក្នុងការអភិវឌ្ឍសហគមន៍របស់ពួកគាត់តាមរយៈគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ(គ.អ.ភ)។ ពួកគាត់ មិនត្រឹមតែមានគំនិតផ្តួចផ្តើមក្នុងការធ្វើឲ្យប្រសើរឡើងនូវជីវភាពរស់នៅ និងក្នុងការដោះស្រាយបញ្ហាប្រឈមនានាក្នុងមូលដ្ឋាន តាមរយៈក្រុម និងគណៈកម្មាធិការផ្សេងៗនោះទេ ពួកគាត់ក៏បានបង្កើតគណៈកម្មាធិការពិសេសមួយដែលហៅថាគណៈកម្មាធិការកិច្ចការរួម។ គោលបំណងរបស់គណៈកម្មាធិការនេះ គឺរកចំណូលសម្រាប់ភូមិ និងអ្នកភូមិរបស់ពួកគាត់ផ្ទាល់ ដោយដាំដើមស្វាយចន្ទីនៅលើផ្ទៃដី ២ហិកតាដែលបានបម្រុងទុកសម្រាប់គណៈកម្មាធិការកិច្ចការរួម។*

គ.អ.ភ កាម៉ែន ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១៦ តាមរយៈការផ្តួចផ្តើមរបស់ភូមិកាម៉ែន និងដោយមានការសម្របសម្រួល និងជួយពីគម្រោងរបស់អាយស៊ីស៊ី អាយប៊ីស៊ីឌីអី (អប់រំ និងអភិវឌ្ឍន៍សហគមន៍ផ្អែកលើអត្តសញ្ញាណ)។ គោលបំណងរបស់ គ.អ.ភ កាម៉ែន គឺដើម្បីគ្រប់គ្រង សម្របសម្រួល និងគាំទ្រដល់ក្រុម និងគណៈកម្មាធិការអភិវឌ្ឍន៍នានានៅក្នុងភូមិ ដើម្បីបង្កើតឥទ្ធិពលដោយបង្រួបបង្រួមកម្លាំង និងសម្រេចបាននូវផលប៉ះពាល់រយៈពេលវែង។ គ.អ.ភ កាម៉ែន ត្រូវបានរៀបចំឡើងជាលក្ខណៈអង្គការសហគមមូលដ្ឋានដែលស្ថិតនៅក្នុងរចនាសម្ព័ន្ធដូច គ.អ.ភ របស់រដ្ឋ។ ទោះបីជាមិនមែនជា គ.អ.ភ របស់រដ្ឋក៏ដោយ គ.អ.ភ កាម៉ែន បាននឹងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងអាជ្ញាធរមូលដ្ឋាន ហើយក៏ត្រូវបានការទទួលស្គាល់យ៉ាងពេញលេញផងដែរ។ គណៈកម្មាធិនេះមានសមាជិកចំនួន ១៨នាក់ដែលតំណាងឲ្យអ្នកភូមិកាម៉ែន ហើយជាមួយគ្នានេះដែល គ.អ.ភ កាម៉ែន ត្រូវបានទទួលស្គាល់ និងកោតសរសើរពីសំណាក់អ្នកភូមិយ៉ាងខ្លាំង។ ឧទាហរណ៍ខ្លះៗនៃក្រុម និងគណៈកម្មាធិការក្នុងមូលដ្ឋានដែល គ.អ.ភ កាម៉ែន បានធ្វើការគាំទ្រ និងសម្របសម្រួលគឺ៖ គណៈកម្មាធិការអនាម័យភូមិ ក្រុមសិល្បៈ ក្រុមយុវជន ក្រុមសន្សំប្រាក់ គណៈកម្មាធិការការពារព្រៃឈើ និងក្រុមការងារភូមិ។

គ.អ.ភ កាម៉ែន ជម្រុញកិច្ចសហប្រតិបត្តិការរវាងមនុស្សចាស់ និងយុវជននៅក្នុងភូមិ ដើម្បីថែរក្សាវប្បធម៌ និងទំនៀមទម្លាប់ទំពួន ហើយក៏បង្កឲ្យមានការចូលរួមពីយុវជនក្នុងកិច្ចការងារសង្គម និងការងារអភិវឌ្ឍន៍។ គ.អ.ភ កាម៉ែន ទទួលបានជោគជ័យក្នុងការកាត់បន្ថយអំពើហិង្សាក្នុងគ្រួសារនៅក្នុងភូមិ ខណៈពេល បុរសកាន់តែច្រើន ប្តេជ្ញាចិត្តចូលរួមក្នុងកិច្ចការផ្ទះ។ លើសពីនេះទៀត គឺមើលឃើញថាឪពុកម្តាយភាគច្រើន បានបញ្ជូនកូនទៅសាលារៀន។ គ.អ.ភ កាម៉ែន ក៏កំពុងធ្វើផែនការសម្រាប់ពេលអនាគតផងដែរ ហើយ គ.អ.ភ កាម៉ែន មានសមត្ថភាពក្នុងការចងភ្ជាប់ជាមួយនឹងដៃគូដែលមានសក្តានុពលផ្សេងៗ ទាំងពីវិស័យរដ្ឋ និងសង្គមស៊ីវិល ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហប្រតិបត្តិការ។

បន្ថែមពីលើទៀត គ.អ.ភ កាម៉ែន កំពុងដើរតួជា គ.អ.ភ គំរូ និងកំពុងចែករំលែកសមត្ថភាពរបស់ខ្លួនទៅកាន់ភូមិដទៃទៀត។ ជាឧទាហរណ៍ សមាជិកខ្លះរបស់ គ.អ.ភ កាម៉ែន កំពុងបង្ហាត់បង្រៀន បច្ចេកទេសស្តីពីការសង់បង្គន់អនាម័យ ហើយសមាជិកដទៃទៀត ក៏កំពុងបង្ហាត់បង្រៀនបច្ចេកទេសដាំដុះ ដើម្បីបានផលច្រើន។ ឥឡូវនេះ ភូមិកាម៉ែន បានប្រែក្លាយទៅជាភូមិមួយដែលមានសុវត្ថិភាព ដោយសារអ្នកភូមិ សកម្មក្នុងការការពារធនធានជាតិរបស់ពួកគាត់ ដូចជាព្រៃឈើជាដើម។

ក្រុមការងារ អាយប៊ីស៊ីឌីអី បានទទួលជោគជ័យក្នុងការបង្កើត គ.អ.ភ ចំនួន១៦ នៅក្នុងចំណោមភូមិគោលដៅចំនួន២៣ រួមមានជនជាតិដើមភាគតិចទំពួន គ្រឹង ព្រៅ និងចារ៉ាយ។ គ.អ.ភ ភាគច្រើន ត្រូវបានបង្កើតជាអង្គការសហគមន៍មូលដ្ឋាន ហើយមួយចំនួនទៀត ត្រូវបានបង្កើតនៅក្នុងរចនាសម្ព័ន្ធរដ្ឋាភិបាល។ គ.អ.ភ ទាំងនេះ កំពុងបង្ហាញពីភាពជាម្ចាស់ និងការប្តេជ្ញាចិត្តជាស្រេចហើយ និងមានលទ្ធភាពបង្ហាត់បង្រៀនបន្ថែម ពង្រឹង និងប្រមូលផ្តុំ គ.អ.ភ ទាំងនេះ ឲ្យទទួលខុសត្រូវពេញលេញសម្រាប់ការងារអភិវឌ្ឍន៍ផ្ទាល់ នៅក្នុងភូមិគោលដៅនីមួយៗ និងកំពុងត្រូវបានទទួលស្គាល់ដោយអាជ្ញាធរថ្នាក់ក្រោមជាតិ។ ក្រុមការងារ អាយប៊ីស៊ីឌីអី នឹងព្យាយាមបង្កើត គ.អ.ភ ឲ្យបានគ្រប់ភូមិគោលដៅទាំង២៣ ដើម្បីធានាថាការងាររបស់អាយប៊ីស៊ីឌីអី នឹងនៅតែបន្តបន្ទាប់ពី គម្រោងអាយប៊ីស៊ីឌីអី បញ្ចប់។

*កាលបរិច្ឆេទ៖ មេសា ២០១៨*